# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ១៥១ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានស្ថិតិទេសចរណ៍ នៃវិទ្យាស្ថានជាតិទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានស្ថិតិទេសចរណ៍ នៃវិទ្យាស្ថានជាតិទេសចរណ៍។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅធានានូវប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យារបស់នាយកដ្ឋានស្ថិតិទេសចរណ៍។

វិមានលេខ៣A ផ្លូវលេខ១១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**ប្រការ ៣.-**

**នាយកដ្ឋានស្ថិតិទេសចរណ៍** ចំណុះវិទ្យាស្ថានជាតិទេសចរណ៍ និងជាសេនាធិការឱ្យក្រសួងទេសចរណ៍ ទទួលបន្ទុកការងារកសាងស្ថិតិទេសចរណ៍ផ្លូវការ ដោយធ្វើការប្រមូល ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយទិន្នន័យស្ថិតិទេសចរណ៍ និងជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទូរគមនាគមន៍ក្នុងវិស័យទេសចរណ៍ សំដៅលើកកម្ពស់គុណភាពការងារឱ្យស្របតាមការវិវត្តរីកចំរើន នៃយុគសម័យបច្ចេកវិទ្យាព័ត៌មាន និងចាំបាច់ដើម្បីរួមចំណែកពង្រឹងគុណភាពស្ថិតិទេសចរណ៍ និងការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព។

**នាយកដ្ឋានស្ថិតិទេសចរណ៍** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំ និងគ្រប់គ្រងការងារស្ថិតិទេសចរណ៍នៅទូទាំងប្រទេស
- ប្រមូល ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិទេសចរណ៍ផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិទេសចរណ៍
- សិក្សាស្រាវជ្រាវ និងវិភាគទិន្នន័យស្ថិតិទេសចរណ៍ និងចងក្រងស្ថិតិទេសចរណ៍តាមវិធីសាស្រ្តផ្សេងៗ ដើម្បីបង្កើនគុណភាពស្ថិតិទេសចរណ៍ផ្លូវការ
- អង្កេតភ្ញៀវទេសចរ កម្លាំងពលកម្ម និងធនធានទេសចរណ៍
- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គភាពស្ថិតិ អាជ្ញាធរពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងផ្នែកឯកជនលើការងារស្ថិតិទេសចរណ៍
- រៀបចំ និងអភិវឌ្ឍប្រព័ន្ធទេសចរណ៍រណប
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់នាយកវិទ្យាស្ថានជាតិទេសចរណ៍។

នាយកដ្ឋានស្ថិតិទេសចរណ៍ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**ប្រការ ៤.-**

នាយកដ្ឋានស្ថិតិទេសចរណ៍ មានការិយាល័យចំណុះចំនួន **០៤ (បួន)** ដូចខាងក្រោម៖

១-ការិយាល័យស្ថិតិទេសចរណ៍

២-ការិយាល័យរៀបចំទិន្នន័យ និងទិន្នន័យមូលដ្ឋាន

៣-ការិយាល័យស្រាវជ្រាវ និងវិភាគស្ថិតិ

៤-ការិយាល័យបច្ចេកវិទ្យាព័ត៌មាន។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន **មួយ(០១)រូប និង**អនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់នាយកដ្ឋានស្ថិតិទេសចរណ៍ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

# ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ ៥.-**

ការិយាល័យនីមួយៗ មានតួនាទី និងភារកិច្ចដូចតទៅៈ

**១-ការិយាល័យស្ថិតិទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- ប្រមូល ចងក្រង រៀបចំរបាយការណ៍ស្ថិតិទេសចរណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ឆ្នាំ
- ធ្វើកិច្ចសហការជាមួយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ ដើម្បីប្រមូលទិន្នន័យស្ថិតិទេសចរនៅតាមគ្រប់បណ្តាច្រកទ្វារព្រំដែនអន្តរជាតិក្នុងក្របខណ្ឌទូទាំងប្រទេស
- ធ្វើអង្កេតទេសចរណ៍ជាតិ អន្តរជាតិ និងកម្លាំងពលកម្មបម្រើការក្នុងវិស័យទេសចរណ៍
- រៀបចំ និងអភិវឌ្ឍគណនីរណបទេសចរណ៍ (Tourism Satellite Account – TSA)
- រៀបចំបោះពុម្ពសៀវភៅរបាយការណ៍ស្ថិតិទេសចរណ៍ប្រចាំឆ្នាំ
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងក្រសួងទេសចរណ៍ ដើម្បីចងក្រងទិន្នន័យឧស្សាហកម្មទេសចរណ៍
- ទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិដូចជា UNWTO, PATA, ASEAN Secretarial, IMF, UNSD, OECD, ESCAP ក្នុងការផ្លាស់ប្តូរទិន្នន័យស្ថិតិ និងធ្វើទំនើបកម្មប្រព័ន្ធទិន្នន័យទេសចរណ៍។

**២-ការិយាល័យរៀបចំទិន្នន័យ និងទិន្នន័យមូលដ្ឋាន** មានតួនាទី និងភារកិច្ចៈ

- ទទួលបន្ទុកការត្រួតពិនិត្យ ការបញ្ចូល ការរៀបចំទិន្នន័យ និងថែរក្សាទិន្នន័យទុកក្នុងទម្រង់ឌីជីថល និងទម្រង់ផ្សេងទៀតឱ្យមានសុវត្ថិភាព
- បង្កើតទម្រង់តារាងសម្រាប់ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យ
- ធ្វើការសំអាតកំហុសទិន្នន័យ និងរៀបចំដាក់លេខកូដសំគាល់
- ពង្រឹងជំនាញក្នុងការរៀបចំទិន្នន័យតាមស្តង់ដាស្ថិតិជាតិ និងអន្តរជាតិ។

**៣-ការិយាល័យស្រាវជ្រាវ និងវិភាគស្ថិតិ** មានតួនាទី និងភារកិច្ចៈ

- រៀបចំចងក្រងវិធីសាស្ត្រ បទដ្ឋាន និងស្តង់ដាស្ថិតិទេសចរណ៍ ដើម្បីធានាដំណើរការផលិតទិន្នន័យស្ថិតិទេសចរណ៍ឲ្យបានត្រឹមត្រូវ មានគុណភាព គួរទុកចិត្តបាន និងទាន់ពេលវេលា
- សិក្សាស្រាវជ្រាវ វិភាគនិន្នាការ និងព្យាករណ៍ទេសចរណ៍
- សិក្សាស្រាវជ្រាវ ចងក្រង ដោយសហការជាមួយផ្នែកពាក់ព័ន្ធនូវវិធីសាស្ត្រផ្សេងៗដូចជា វិធីសាស្ត្រជ្រើសរើសគំរូ វិធីសាស្ត្រអភិវឌ្ឍម៉ូដែល វិធីសាស្ត្រកែតម្រូវតាមរដូវកាល វិធីសាស្ត្រប៉ាន់ស្មាន និងវិធីសាស្ត្រដ៏ទៃទៀតតាមតម្រូវការជាក់ស្តែង
- រៀបចំកម្រងសំណួរអង្កេតទេសចរណ៍ និងផ្តល់ប្រឹក្សាយោបល់ក្នុងការប្រមូលទិន្នន័យ
- សិក្សាស្រាវជ្រាវ វិភាគប្រភពព័ត៌មានស្ថិតិ ដើម្បីកំណត់ទីផ្សារទេសចរណ៍ សំដៅបម្រើឱ្យកិច្ចការរៀបចំផែនការ សិក្សាទីផ្សារនិងផ្សព្វផ្សាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍
- ធ្វើការបណ្តុះបណ្តាលមន្ត្រីជំនាញតាមបណ្តាមន្ទីរទេសចរណ៍រាជធានី ខេត្ត ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រីជំនាញស្ថិតិ។

**៤-ការិយាល័យបច្ចេកវិទ្យាព័ត៌មាន** មានតួនាទី និងភារកិច្ចៈ

- ធ្វើកិច្ចសហការ និងសម្របសម្រួលរៀបចំគោលនយោបាយអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន គមនាគមន៍ ដើម្បីអនុវត្តរដ្ឋាភិបាលអេឡិចត្រូនិច (e-Government) ក្នុងវិស័យទេសចរណ៍
- ធ្វើកិច្ចសហការ និងសម្របសម្រួលក្នុងសកម្មភាពអភិវឌ្ឍន៍កម្មវិធី Software បម្រើឱ្យវិស័យទេសចរណ៍
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន គមនាគមន៍ ក្នុងវិស័យទេសចរណ៍

- គ្រប់គ្រងការប្រើប្រាស់ និងចែកចាយអ៊ីនធឺណេតផ្ទៃក្នុងក្រសួង
- រៀបចំលក្ខណៈបច្ចេកទេសដើម្បីធានាពីភាពអាចប្រាស្រ័យទាក់ទងគ្នាបាននៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងក្រសួង និងមន្ទីរទេសចរណ៍រាជធានី ខេត្ត
- រៀបចំចងក្រងបង្កើតប្រព័ន្ធទិន្នន័យទេសចរណ៍ (Tourism Database)
- រៀបចំលក្ខណៈបច្ចេកទេសដើម្បីធានាសន្តិសុខព័ត៌មាននៃប្រព័ន្ធទិន្នន័យទេសចរណ៍
- ត្រួតពិនិត្យសម្ភារៈបរិក្ខាផ្នែករឹង និងផ្នែកទន់ ដើម្បីឆ្លើយតបនឹងតម្រូវការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន គមនាគមន៍។

**ប្រការ ៦.-**

ការិយាល័យនីមួយៗ ចំណុះឱ្យនាយកដ្ឋានស្ថិតិទេសចរណ៍ មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការសកម្មភាពការងារ និងគម្រោងចំណាយប្រចាំឆ្នាំរបស់ខ្លួនជូនប្រធាននាយកដ្ឋាន
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ របស់ការិយាល័យជូនប្រធាននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធាននាយកដ្ឋានស្ថិតិទេសចរណ៍ ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ